00647911

E9/4/3/2

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ការជូនដំណឹងរបស់លោក អៀង សារី រក្សាសិទ្ធិជំទាស់នៅលើសាក្សី និងអ្នកជំនាញដែលបាន ស្នើដោយដើមបណ្តឹងរដ្ឋប្បវេណី

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តារ៉ា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / 02 / 2011
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះ សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា គាត់សូមរក្សាសិទ្ធិដើម្បីជំទាស់ទៅលើសាក្សី និងអ្នកជំនាញទាំងឡាយដែលបានស្នើឡើងដោយ ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីទាំងឡាយផ្សេងទៀត។ មេធាវីការពារក្តី នៅពេលនេះ មិនស្ថិតនៅក្នុងស្ថានភាពមួយដែលត្រូវជំទាស់អោយបានពេញលេញបរិបូរទៅលើសាក្សី ឬ អ្នកជំនាញដែលបានស្នើឡើងទាំងនេះឡើយ[1]។ មេធាវីការពារក្តីទើបត្រូវបានគេជូនដំណឹងអំពីបញ្ជីសាក្សី និងអ្នកជំនាញមួយចំនួននៅត្រឹមថ្ងៃទី ២២ កុម្ភៈ ២០១១ ប៉ុណ្ណោះ។ មេធាវីការពារក្តីមិនទាន់ត្រូវបានគេជូនដំណឹងនៅឡើយទេ អំពីអង្គហេតុអ្វីខ្លះដែលភាគច្រើននៃសាក្សីដែលបានស្នើសុំទាំងនេះនឹងត្រូវឡើងមកផ្តល់សក្ខីកម្មឡើយ ឬ ជូនដំណឹងអំពីគុណវុឌ្ឍិនានានៃអ្នកជំនាញមួយចំនួនធំទាំងឡាយដែលបានស្នើសុំឡើយ[2]។ ហេតុដូច្នេះ មេធាវីការពារក្តី ត្រូវតែរក្សាសិទ្ធិដើម្បីជំទាស់ទៅលើសាក្សី និងអ្នកជំនាញទាំងនេះ រហូតដល់ពេលដែលមេធាវីការពារក្តី បានទទួល និងបានធ្វើវិភាគទៅលើសេចក្តីសង្ខេបទាំងនេះ។

សូមលោកចៅក្រមអង្គជំនុំសាលាដំបូងទទួលសេចក្តីជូនដំណឹងនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

---

[1] ក្រុមមេធាវីការពារក្តី ពិតជាមានបំណងជំទាស់ទៅលើអ្នកជំនាញមួយចំនួនដែលបានស្នើឡើងនៅពេលនេះ ប៉ុន្តែដោយសារក្រុមមេធាវីការពារក្តីបានពន្យល់នៅក្នុងការដាក់ឯកសារដោយឡែកទាំងនេះ ក្រុមមេធាវីការពារក្តីមិនទាន់មានព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើការជំទាស់អោយបានពេញលេញឡើយ។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តី បានស្នើសុំការពន្យារពេលបន្ថែមដើម្បីដាក់ការជំទាស់បន្ថែមបើសិនជាចាំបាច់។

[2] មកទល់ថ្ងៃនេះ មេធាវីការពារក្តីបានទទួលត្រឹមតែសេចក្តីសង្ខេបរបស់ក្រុមមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ ប៉ុណ្ណោះ។ *សូមមើល ករណី* អៀង ធីរិទ្ធ សំណុំរឿង ០០២-១៩-០៩-២០០៧-អវតក/អជសដ, ព័ត៌បន្ថែមរបស់ អៀង ធីរិទ្ធ ស្តីពីសាក្សី និងអ្នកជំនាញ ចុះថ្ងៃទី ២៣ កុម្ភៈ ២០១១ ឯកសារលេខ E9/9, ERN: 00645024-00645026។